ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៦១ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី ប្រជាពលរដ្ឋ ដែលប៉ះពាល់ដោយសារគំរោងស្តារឡើងវិញកំណាត់ ផ្លូវជាតិលេខ ៦១ ក្នុងខេត្ត (កណ្តាល-កំពង់ចាម)

*************

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤.អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ០០៣ សក. ៥២៥ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១០ លើលិខិតលេខ ៧៨២ សហវ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លិខិតលេខ ៨៣២ សក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១០ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ ៣១០ ដនស,អរប,ឆត ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតំរូវការចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១** ÷បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីពិនិត្យ និងវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសម្បែង ដីធ្លី របស់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងសាងសង់ផ្លូវជាតិលេខ ៦១ ក្នុងខេត្តកណ្តាល និងខេត្តកំពង់ចាម ។

**ប្រការ២** ÷គណៈកម្មការអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម **ចឹម សម្បត្តិថាវ័ត្ត** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៣-ឯកឧត្តម **ខាវី ចិត្សុត** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក **គី សុភាត់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសាធារណការនៃក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៥-លោកបណ្ឌិត **ឈន សុភាព** | ប្រធាននាយកដ្ឋាន Resettlement នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក **ស៊ុម សំណាង** | អនុប្រធាននាយកដ្ឋាន Resettlement នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោក **ស៊ុំ សុគង់** | ប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨-លោក **ម៉ែន ដារ៉ាមុនី** | ប្រធានការិយាល័យគំរោងទ្វេភាគី នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោក **ហ៊ឹម បញ្ញាធុរុណ្ណ** | ប្រធានការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ៣** ÷គណៈកម្មការអន្តក្រសួងមានភារៈកិច្ចចុះពិនិត្យដល់ទីកន្លែងគម្រោង ធ្វើស្ថិតិរៀបចំចងក្រងទិន្នន័យសំណង់ផ្ទះសម្បែង ដីធ្លី របស់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគំរោងស្តារឡើងវិញផ្លូវជាតិលេខ ៦១ ក្នុងខេត្តកណ្តាល និងកំពង់ចាម និងធ្វើការវាយតំលៃទ្រព្យសម្បត្តិដែលរងនូវផលប៉ះពាល់ទាំងនោះ សំរាប់ចងក្រងជាសៀវភៅផែនការសកម្មភាពនៃការតាំងទីលំនៅឡើងវិញ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសំរេចដែលជាមូលដ្ឋានសំរាប់ដោះស្រាយគោលនយោបាយជូនដល់ប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងខាងលើ ។

**ប្រការ៤** ÷គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារ សំរាប់បំពេញការងារប្រចាំថ្ងៃនៅតាមទីតាំងភូមិសាស្ត្រនៃគម្រោងខាងលើ ។

**ប្រការ៥** ÷សាមីខ្លួន នាយកដ្ឋានដោះស្រាយផលប៉ះពាល់ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារៈកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ចម្លងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសាធារណការ និងដឹកជញ្ជូន
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-សាលាខេត្តកណ្តាល និងកំពង់ចាម
-ដូចប្រការ៥ ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ